# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២

# លោកជំទាវ Kathryn Campbell រដ្ឋលេខាធិការក្រសួងការបរទេស និង ពាណិជ្ជកម្ម របស់ប្រទេសអូស្ត្រាលី មកទស្សនកិច្ចនៅកម្ពុជា

លោកជំទាវ Kathryn Campbell រដ្ឋលេខាធិការក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី នឹងមកបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី១២ ដល់ ថ្ងៃទី១៤ ខែមិថុនា។ ដំណើរទស្សនកិច្ចនេះធ្វើឡើង ក្នុងខណៈពេលយើងកំពុងប្រារព្ធខួបលើកទី៧០ឆ្នាំ នៃចំណងការទូតរវាងប្រទេសអូស្ត្រាលី និងកម្ពុជា  និងក្នុងពេលដែលកម្ពុជាជាប្រធានអាស៊ាន។

លោកជំទាវ រដ្ឋលេខាធិការ Campbell នឹងជួបជាមួយ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រួមទាំងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀត របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ក្នុងដំណើរទស្សនកិច្ចរបស់លោកជំទាវនេះ។

លោកជំទាវ រដ្ឋលេខាធិការ Campbell ក៏នឹងជួបជាមួយ ឯកឧត្តម បណ្ឌិត កៅ គឹមហួន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ឯកឧត្តម លី ធុច ទេសរដ្ឋមន្ត្រី និងជាអនុប្រធានទី១ របស់អាជ្ញាធរមីន។

លោកជំទាវ រដ្ឋលេខាធិការ Campbell បានមានប្រសាសន៍ថា "អូស្ត្រាលី និងកម្ពុជាមានទំនាក់ទំនងដ៏រឹងមាំ និងយូរអង្វែង រយៈពេល៧០ឆ្នាំ មកហើយ។ យើងទន្ទឹងរង់ចាំបន្តធ្វើការរួមគ្នាទៅមុខទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ក្នុងតំបន់ និងសកលលោក និងគាំទ្រដល់កម្ពុជាដែលជាប្រធានអាស៊ានក្នុងឆ្នាំនេះ។ ចក្ខុវិស័យរបស់អាស៊ានក្នុងការគាំទ្រឥណ្ឌូប៉ាស៊ីហ្វិកដែល បើកចំហ ប្រកបដោយបរិយាបន្ន និងមានភាពធន់ ជាការសំខាន់ណាស់ចំពោះតំបន់របស់យើង។"

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au